**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ក្រសួងឧស្សាហកម្ម និងសិប្បកម្ម</u>

ភ្នំពេញ-ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦៖ **ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម** បានអញ្ជើញជាសាក្សី នៃពិធីចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យមាត្រាសាស្ត្ររវាងមជ្ឈមណ្ឌលមាត្រាសាស្ត្រកម្ពុជា (NMC) និងវិទ្យាស្ថានមាត្រាសាស្ត្រជាតិ នៃប្រទេសចិន (NIM) ។




ហត្ថលេខី ក្នុងពធីនេះ ភាគីកម្ពុជា ចុះហត្ថលេខាដោយលោកជំទាវ ពៅ វលក្សណ៍ ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិកម្ពុជានិងភាគីចិន ចុះហត្ថលេខាដោយឯកឧត្តមបណ្ឌិត Duan Yunning នាយករងនៃវិទ្យាស្ថានមាត្រាសាស្ត្រជាតិ នៃប្រទេសចិន នៅសាលប្រជុំមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិកម្ពុជា មានទីតាំងនៅ គីឡូម៉ែត្រលេខ ០៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

មានប្រសាសន៍ ក្នុងជំនួបទ្វេភាគី ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានចាត់ទុកអនុស្សារណៈយោគយល់គ្នានេះមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ក្នុងបរិបទនៃសហគមន៍សេដ្ឋកិច្ចអាស៊ាននិងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ពីឆ្នាំ ២០១៥-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងន័យជម្រុញឲ្យការធ្វើពាណិជ្ជកម្មដោះដូរទំនិញ ឲ្យមានភាពស្មោះត្រង់ និងទំនិញ រឺផលិតផលប្រកបដោយគុណភាព និងសុវត្ថភាព ជានាបានភាពសុក្រឹតទាំងផ្នែកទំងន់ ខ្នាត និងរង្វាស់រង្វាល់ផ្សេងៗ ។




ឯកឧត្តមបណ្ឌិត Duan Yunning នាយករងនៃវិទ្យាស្ថានមាត្រាសាស្ត្រជាតិ នៃប្រទេសចិន លើកឡើងពីទំនាក់ទំនងដ៏ល្អ និងយូរអង្វែង រវាងកម្ពុជា-ចិន និងបង្ហាញនូវជំហរគាំទ្រសហការ ហើយពិនិត្យលទ្ធភាពជួយ តាមការស្នើសុំរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ទាក់ទងនិងការផ្តល់កូនទំងន់ជញ្ជីងសម្រាប់ប្រើប្រាស់អនុវត្តការងារធ្វើព្យាសកម្មផ្នែកទំងន់ និងឧបករណ៍ សំភារៈពិសោធន៍ ដ៏ទៃទៀត ។ សូមបញ្ជាក់ថា:ខ្លឹមសារនៃអនុស្សារណៈយោគយល់គ្នានេះ មានវិសាលភាពគ្របដណ្តប់លើវិស័យអាទិភាពមួយចំនួន ដូចជា: ការបណ្តុះបណ្តាលធន់ធានមនុស្សវិស័យមាត្រាសាស្ត្រ -ជំនួយបច្ចេកទេស-ធ្វើឲ្យប្រសើរនូវឧបករណ៍មាត្រាសាស្ត្រដែលមានស្រាប់ និងការបំពាក់ឧបករណ៍ថ្មី ៕

*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ














*រៀបចំដោយ៖ នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន*